

# ជំងឺ COVID-19
# ការពិតនៃថ្នាំបង្ការ

### ថ្នាំបង្ការទាំងឡាយការពារប្រឆាំងនឹងការកើតមានលទ្ធផលដែលមិនល្អបំផុតដោយសារជំងឺ COVID-19។



- ថ្នាំបង្ការជំងឺ COVID-19 កាត់បន្ថយហានិភ័យរបស់អ្នកក្នុងការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារជំងឺ COVID-19 ការត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬការស្លាប់ផងដែរ។ ថ្នាំបង្ការក៏ជួយកាត់បន្ថយហានិភ័យរបស់អ្នកក្នុងការកើតមានជំងឺ COVID រយៈពេលវែង (long COVID) ផងដែរ។
- ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer ប្រភេទ Moderna និងប្រភេទ Novavax គឺបាន **ធ្វើឱ្យថ្មីឡើងវិញ** ដើម្បីការពារប្រឆាំងនឹងពូជមេរោគដែលកើតមាននាពេលថ្មីៗនេះ។
- ថ្នាំបង្ការដែលបានធ្វើឱ្យថ្មីឡើងវិញនេះអាចបង្កើនប្រព័ន្ធការពារពីពេលមុនមក (ពីការចាក់ថ្នាំបង្ការ ឬការឆ្លងមេរោគពីពេលកន្លងមក) ដែលអាចនឹងចុះអន់ថយទៅតាមពេលវេលា។




**មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 6 ខែឡើងទៅ គួរតែទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលបានធ្វើឱ្យថ្មីឡើងវិញ (updated COVID-19 vaccine) នេះ។**



- **កុមារទាំងឡាយដែលមានអាយុចាប់ពី 6 ខែ ទៅ 4 ឆ្នាំ** គួរតែមានការពិភាក្សាជាមួយនឹងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់ពួកគេអំពីចំនួនដូសថ្នាំបង្ការដែលពួកគេត្រូវការទទួលចាក់។ ចំនួននេះគឺអាស្រ័យទៅលើចំនួនដូសថ្នាំបង្ការដែលពួកគេបានទទួលចាក់ពីឆ្នាំមុនៗ។
- **មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 5 ឆ្នាំឡើងទៅ** គួរតែទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលបានធ្វើឱ្យថ្មីឡើងវិញចំនួនមួយដូស។
- **អ្នកដែលមានប្រព័ន្ធភាពសុំាចុះខ្សោយ** អាចនឹងត្រូវការទទួលចាក់ដូសថ្នាំបង្ការដែលបានធ្វើឱ្យថ្មីឡើងវិញនេះបន្ថែមទៀត។ ចូរពិភាក្សាជាមួយនឹងគ្រូពេទ្យរបស់អ្នកថាតើកាលវិភាគនៃការចាក់ថ្នាំបង្ការបែបណាដែលល្អបំផុតសម្រាប់អ្នក។
- ប្រសិនបើអ្នកមាន **អាយុចាប់ពី 65 ឆ្នាំឡើងទៅ** ឬប្រឈមនឹង **ហានិភ័យខ្ពស់ក្នុងការកើតមានជំងឺកម្រិតធ្ងន់ធ្ងរ** ឬក៏ **មិនធ្លាប់បានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ពីមុនមកទេនោះ** ការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលបានធ្វើឱ្យថ្មីឡើងវិញរបស់អ្នកគឺជាចំណុចសំខាន់ជាពិសេស។
- មនុស្សគ្រប់រូបគួរតែទទួលចាក់ថ្នាំបង្ការ បើទោះបីជាពួកគេ **មានផ្ទៃពោះ** ឬ **កំពុងបំបៅកូនដោយទឹកដោះ** ឬក៏ **ធ្លាប់មានជំងឺ COVID-19 រួចហើយក៏ដោយ**។
- សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ cdc.gov/coronavirus/vaccine។

# ជំងឺ COVID-19
# ការពិតនៃថ្នាំបង្ការ

## ទីកន្លែងទទួលចាក់ថ្នាំបង្ការ

ប្រសិនបើអ្នកមានធានារ៉ាប់រងសុខភាព សូមទាក់ទងទៅកាន់អ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នក ដើម្បីកំណត់ពេលវេលាណាត់ជួបសម្រាប់ចាក់ថ្នាំបង្ការ។ ចាប់ផ្តើមពីខែតុលា ឆ្នាំ 2024 នេះទៅ អ្នកមិនមានធានារ៉ាប់រងសុខភាពគឺអាចរកថ្នាំបង្ការដែលមិនគិតថ្លៃបាននៅតាមទីតាំងជាក់លាក់ផ្សេងៗ។ កំណត់សម្គាល់៖ អនីតិជន (ជនមិនទាន់គ្រប់អាយុ) ចាំបាច់ត្រូវមានការអនុញ្ញាតពីឪពុក ឬម្តាយ ឬក៏អាណាព្យាបាលស្របច្បាប់របស់ពួកគេ ដើម្បីទទួលចាក់ថ្នាំបង្ការ។



ដើម្បីស្វែងរកទីតាំងមួយនៅក្នុងតំបន់ជិតអ្នក សូមចូលទៅកាន់គេហទំព័រ ph.lacounty.gov/vaccines ឬក៏ទូរស័ព្ទទៅកាន់លេខ **1-833-540-0473** ឬលេខ **2-1-1**។

ការចាក់ថ្នាំបង្ការនៅតាមផ្ទះគឺអាចរកបាន ហើយអាចស្នើសុំបានតាមរយៈការទូរស័ព្ទទៅកាន់លេខ **1-833-540-0473** ឬក៏ការចូលទៅកាន់គេហទំព័រ VaccinateLACounty.com ហើយចុចនៅលើផ្នែក In-Home Vaccines (ការចាក់ថ្នាំបង្ការនៅតាមផ្ទះ)។

## ផលប៉ះពាល់កម្រិតធ្ងន់ធ្ងរគឺកម្រនឹងកើតមាន។

- ផលប៉ះពាល់ដែលកើតមានជាទូទៅរួមមានការឈឺ ឡើងហើម ឬឡើងក្រហមនៅនឹងកន្លែងដែលបានចាក់ថ្នាំបង្ការនេះ ឈឺសាច់ដុំឬឈឺតាមសន្លាក់ ឡើងហើមកូនកណ្តុរ គ្រុនក្តៅ គ្រុនរងា ឈឺក្បាល និងមានអារម្មណ៍អស់កម្លាំង។ ផលប៉ះពាល់ចំពោះកុមារតូចៗក៏រួមមានការឆាប់យំ ឆាប់ខឹង ងងុយគេង និងបាត់បង់ចំណង់អាហារផងដែរ។
- ផលប៉ះពាល់ទាំងឡាយគឺជាសញ្ញាដែលបង្ហាញថាប្រព័ន្ធភាពស៊ាំរបស់អ្នកកំពុងតែ **បង្កើតប្រព័ន្ធការពារ**។ ផលប៉ះពាល់ទាំងនេះអាចនឹងធ្វើឱ្យមានការរំខានដល់ការធ្វើសកម្មភាពប្រចាំថ្ងៃមួយចំនួនរបស់អ្នក ប៉ុន្តែគួរតែបាត់ទៅវិញក្នុងរយៈពេលមួយ ឬពីរថ្ងៃ បន្ទាប់ពីបានចាក់ថ្នាំបង្ការរួច។
- ផលប៉ះពាល់កម្រិតធ្ងន់ធ្ងរគឺកម្រនឹងកើតមាន។







## ថ្នាំបង្ការជំងឺ COVID-19 គឺមានសុវត្ថិភាព និងមានប្រសិទ្ធិភាព។

- អ្នកមិនអាចកើតជំងឺ COVID-19 ដោយសារថ្នាំបង្ការនោះទេ។ មិនមានថ្នាំបង្ការប្រភេទណាមួយមានផ្ទុកមេរោគដែលបណ្តាលឱ្យកើតជំងឺ COVID-19 ឡើយ។
- ថ្នាំបង្ការទាំងឡាយគឺបានសាកល្បងទៅលើមនុស្សរាប់ម៉ឺននាក់ រួមទាំងអ្នកដែលមិនមែនជាជនជាតិស្បែកស (people of color) មនុស្សវ័យចំណាស់ និងអ្នកដែលមានបញ្ហាសុខភាពប្រចាំខ្លួនផងដែរ ហើយបានរកឃើញថា **មានសុវត្ថិភាព និងមានប្រសិទ្ធិភាព**។
- ចាប់តាំងពីខែធ្នូ ឆ្នាំ 2020 មក **មនុស្សរាប់លាននាក់** បានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដោយសុវត្ថិភាព។
- ថ្នាំបង្ការជំងឺ COVID-19 បន្តឆ្លងកាត់ **ការតាមដានពិនិត្យផ្នែកសុវត្ថិភាពយ៉ាងល្អិតល្អន់** បំផុតនៅក្នុងប្រវត្តិសាស្ត្រសហរដ្ឋអាមេរិក។
- មិនមានភស្តុតាងណាមួយដែលបង្ហាញថាថ្នាំបង្ការជំងឺ COVID-19 បណ្តាលឱ្យមានបញ្ហាមិនអាចមានកូននោះទេ។ ថ្នាំបង្ការទាំងនេះគឺមានសុវត្ថិភាពសម្រាប់អ្នកដែលមានផ្ទៃពោះ និងត្រូវបានណែនាំឱ្យទទួលចាក់ដោយអ្នកជំនាញផ្នែកផ្ទៃពោះ ផងដែរ។